# ជំនឿនិងការគោរពប្រតិបត្តិយាយទេពក្នុងសង្គមខ្មែរ

ក្នុងចំណោមអមនុស្សនៃជំនឿខ្មែរ "យាយទេព" គឺជាអមនុស្សភេទស្រីដ៏ល្បីល្បាញ ដែលគេស្គាល់ថា យ៉ាងហោចមានរូបសំណាកតាំងនៅពីរកន្លែង គឺនៅវត្តយាយទេពក្នុងខេត្តកំពង់ឆ្នាំង និងនៅកណ្ដាលក្រុងសៀមរាប។ រូបសំណាកទាំងពីរហាក់មានសណ្ឋានពុំដូចគ្នាឡើយ ពោលគឺយាយទេពនៅកំពង់ឆ្នាំង ជាស្ត្រីសម្បូរទ្រព្យស្ដុកស្ដម្ភ អាស្រមស្កឹមស្កៃ (រូបលេខ១) ឯយាយទេពនៅសៀមរាប គឺជារូបដែលអ្នកស្រាវជ្រាវយល់ថាជាបដិមា "ព្រះយម" ឬអ្នកផងខ្លះហៅថា "ស្ដេចគម្វង់" (រូបលេខ២)។[១] ប៉ុន្តែបើមើលហួសពីនោះ សព្វថ្ងៃគេតែងសង្កេតឃើញនៅក្នុងវត្តនានាផ្សេងទៀត តែងតែតម្កល់រូបសំណាកយាយទេពមានសណ្ឋានផ្សេងៗគ្នា នៅក្នុងខ្ទម ឬតម្កល់ក្រោមដើមឈើណាមួយក្បែរព្រះវិហារ។ តើកត្តាអ្វីខ្លះដែលធ្វើឱ្យឥទ្ធិពល និងវត្តមានយាយទេពសាយភាយយ៉ាងរហ័ស?



រូបលេខ១ អាស្រមយាយទេពនៅកំពង់ឆ្នាំង



រូបលេខ២ អាស្រមយាយទេពនៅសៀមរាប

ជាការពិត យាយទេពក៏ជាអ្នកតាដែរ[២] តែហាក់ពុំមានឥទ្ធិពល ឬវិសាលភាពពាក់ព័ន្ធនឹងស្រែចម្ការទេ ពោលគឺប្រហែលពុំមានឡើយពិធីឡើងអ្នកតា ធ្វើថ្វាយចំពោះយាយទេព

---

[១] ហឿន សុវណ្ណមរកត "ជំនឿលើព្រះគម្វង់មុខវត្តឧណ្ណាលោម" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/25553 ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

[២] អ្នកស្រែតែងប្រារព្ធពិធីឡើង "អ្នកតា" មុននិងក្រោយរដូវធ្វើស្រែ (សូមអាន៖ អាំង ជូលាន ២០០០)

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ដូចទំនៀមអ្នកស្រែដែលតែងធ្វើពិធីឡើងអ្នកតាប្រចាំភូមិស្រុករបស់គេរៀងរាល់ឆ្នាំនោះទេ។[៣] ប៉ុន្តែបើមើលស៊ីជម្រៅ នាទីរបស់យាយទេពភាគច្រើនគឺនៅមិនហួសពីព្រំដែនវត្តលើកលែងតែយាយទេពដ៏ល្បីនៅកណ្ដាលក្រុងសៀមរាប ដែលសព្វថ្ងៃហាក់មាននាទីសំខាន់ក្នុងជំនឿខ្មែរ និងអ្នកទេសចរ។ ប៉ុន្តែយ៉ាងណាក្ដី មុននឹងនិយាយលម្អិតវែងឆ្ងាយពាក់ព័ន្ធនឹងឥទ្ធិពលយាយទេពក្នុងសង្គមបច្ចុប្បន្ន ខ្ញុំសូមលើកនិយាយអំពីយាយទេពនៅកណ្ដាលក្រុងសៀមរាប និងយាយទេពស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំងជាមុន។

ចំពោះយាយទេពស្ថិតក្នុងក្រុងសៀមរាប តម្កល់នៅរង្វង់មូលជិតព្រះរាជដំណាក់ក្បែរទីសក្ការៈព្រះអង្គចេកព្រះអង្គចម គឺជាបដិមាដែលគេយល់ថាមានទំនាក់ទំនងទៅនឹងអ្នកតា "តាគង់" ដែលស្ថិតនៅក្នុងវត្តខ្នាត ក្បែរបារាយណ៍ខាងលិច។[៤] អ្នកស្រាវជ្រាវជាតិបារាំងម្នាក់ឈ្មោះ *Lunet de Lajonquière* សិក្សាថា វត្តនេះកសាងនៅលើបុរាណដ្ឋានចាស់ ដែលមានសំណង់ប្រាសាទសង់ក្នុងសម័យមុនអង្គរ និងសង់បន្ថែមក្នុងសម័យអង្គរ។ លើសពីនេះលោកបញ្ជាក់ថា នៅវត្តខ្នាតមានចម្លាក់មួយធំចម្លងពីបដិមាស្ដេចគម្លង់នៅក្នុងក្រុងអង្គរធំ (រូបលេខ៣)។[៥] មិនតែប៉ុណ្ណោះ អ្នកស្រុកចំណុះជើងវត្តខ្នាតនៅចាំ និងនិយាយតៗគ្នាថា "តាគង់" ត្រូវគេដឹកតាមរទេះទៅដល់មុខព្រះរាជដំណាក់ក្រុងសៀមរាប ក៏សម្រាកមួយយប់ ហើយត្រូវគេលួចកាត់



***រូបលេខ៣ រូបសំណាកតាគង់នៅវត្តខ្នាត***

**(ប្រភព៖ *EFEO*)**

---

[៣] សូមស្ដាប់បទបង្ហាញអំពី "អមនុស្សក្នុងជំនឿខ្មែរ" ដោយនរវិទូ អាំង ជូលាន រៀបចំដោយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។ សូមអានបន្ថែមផងដែរ "មនុស្ស និងដី" ឆ្នាំ២០០០, ដោយនរវិទូ អាំង ជូលាន។

[៤] សូមអានបន្ថែម "តាគង់ និងពិធីឡើងមាយនៅវត្តខ្នាត" ដោយ អ៊ូ គង្គា ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/27077 ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

[៥] *Etienne Lunet de Lajonquière 1911: 281-282*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្បាលបាត់ ទើបគេរក្សាទុកនៅទីនោះរហូតមក។

បើតាមការសិក្សាមួយផ្សេងៗទៀតឱ្យដឹងថា នៅដើមឆ្នាំ១៩៣០ រេស៊ីដង់បារាំងប្រចាំខេត្តសៀមរាប បានយកបដិមាខាងលើមកដាក់តាមបណ្ដោយផ្លូវជាតិលេខ៦ នៅជិតមាត់ស្ទឹង។ លុះដល់សម័យខ្មែរក្រហម គេបានយកបដិមានោះទៅទម្លាក់ចូលស្រះក្នុងវត្តដំណាក់ ហើយនៅឆ្នាំ១៩៨៥ ទើបគេយកទៅដាក់នៅទីតាំងដើមវិញ។[៦] ប៉ុន្តែយ៉ាងណាក្តីអ្នកស្រាវជ្រាមើលឃើញថា បដិមាខាងលើដែលបារាំងយល់ថាចម្លងពីស្តេចគម្ពង់ក្រុងអង្គរធំ ឬអ្នកស្រុកហៅថា "តាគង់" គឺជា "ព្រះយម" ឬ "ព្រះយមរាជ" ដែលខ្មែរស្គាល់តាំងពីបុរាណ ពោលគឺតាំងពីខ្មែរទទួលអារ្យធម៌ឥណ្ឌាម្ល៉េះ ហើយទុកជាទេពយ៉ាងសំខាន់ក្នុងជំនឿ ដោយមានឆ្លាក់រូបនៅតាមប្រាសាទច្រើនកន្លែងរាប់ពុំអស់។ ជាទូទៅគេឆ្លាក់ទេពអង្គនេះ គង់លើក្របី (ជួនក្របីក្បាលបី) ដៃកាន់ដំបង។ ឧទាហរណ៍នេះ គេឃើញច្បាស់នៅត្រង់ចម្លាក់ឋានសួគ៌-នរក លើជញ្ជាំងខាងត្បូងនៃប្រាសាទអង្គរវត្ត ឆ្លាក់ជារូបធំមានដៃ១៨ កាន់ដំបងស្ទើរទាំងអស់ ហើយគង់លើក្របី មានចារអក្សរនៅជិតនោះថា "ព្រះ



***រូបលេខ២ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*** និង ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** សព្វព្រះរាជហឫទ័យថ្វាយផ្កា និងគ្រឿងសក្ការៈរូបសំណាកយាយទេព (ឆ្នាំ២០១៨),

**(ប្រភព៖ www.norodomsihamoni.org)**

---

៦ *Hang Chansophea 2004: 116* និងសូមអានបន្ថែម "តាគង់ និងពិធីឡើងមាយនៅវត្តខ្នាត" ដោយ អ៊ូ គង្គា ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/27077 ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

យម” (ព្រះយម)។[៧] ចំពោះពាក្យហៅបដិមាខាងលើ ដែលតម្កល់ក្បែរព្រះរាជដំណាក់ក្នុងក្រុងសៀមរាបថា “យាយទេព” គឺហាក់ពុំទាន់មានប្រភពសិក្សាបញ្ជាក់ថាហៅចាប់ពីពេលណា ឬហៅបែបនេះដោយសារអ្វីឡើយ។ ប៉ុន្តែអ្វីដែលកាន់តែវិសេសគួរឱ្យកត់សម្គាល់ ***ព្រះមហាក្សត្រជាអម្ចាស់*** និង ***សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ*** ស្តេចតែងយាងថ្វាយគ្រឿងសក្ការៈរូបសំណាកយាយទេព និងព្រះអង្គចេកព្រះអង្គចមក្នុងព្រះរាជដំណើររបស់ទ្រង់យាងទៅកាន់ខេត្តសៀមរាប (រូបលេខ២៤)។

ចំណែកសំណែនដែលគេសម្គាល់ឃើញអ្នកផងតែងថ្វាយយាយទេព គឺ “មាន់ផ្កាង”។ មាន់នោះមានឈ្មោះថាមាន់មែន តែពុំមានសាច់ឡើយ គឺមានតែស្បែកនិងរោមដែលគេពន្លាត់យកសាច់ចេញ ហើយដោតឫស្សីផ្កាងឱ្យឃើញដូចមាន់មួយទាំងមូលប៉ុណ្ណោះ។ បើផ្អែកតាមរូបថតឯកសារកាលពីប្រហែលជិត២០ឆ្នាំមុន គេឃើញថាសំណែនមាន់ផ្កាងចំពោះយាយទេពសម្បូរក្រៃលែង (រូបលេខ២៥)។ ប៉ុន្តែយ៉ាងណាក្តី មកដល់សព្វថ្ងៃគេនៅតែឃើញអ្នកមានជំនឿចូលថ្វាយមាន់ផ្កាងជារឿយៗថ្វីត្បិតតែពុំសូវសម្បូរច្រើនដូចកាលកន្លង។ តាមការសង្កេតកិច្ចរបស់អ្នកភូមិ សំណែនមាន់ផ្កាងបែបនេះគេច្រើនរៀបចំក្នុងបណ្តាសំណែនផ្សេងៗទៀតសម្រាប់ “បញ្ជូន” ទៅដល់ពពួកខ្មោចថោកទាបដែលគេពុំរាប់រក តែអាចមក “ដោយពោយ” តាមគេឯងរំខានដល់កិច្ចពិធី។[៨] ចំពោះសំណែនផ្សេងទៀតសម្រាប់យាយទេព គឺគ្រឿងតុបតែងខ្លួនប្រាណរបៀបបែប



**រូបលេខ២៥ សំណែនមាន់ផ្កាងចំពោះយាយទេព កាលជិត២០ឆ្នាំមុន (រូបថត៖ *Keiko Miura*)**

---

[៧] ចំពោះដំណើររឿងព្រះយម សូមអាន អាំង ជូលាន ២០០៧: ២៦-២៧

[៨] អាំង ជូលាន ២០១២-២០១៣: ៣២-៣៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



មនុស្សស្រីដូចជា សម្លៀកបំពាក់ ក្រាស កញ្ចក់ ក្រែម ប្រេង ម្សៅ និងទឹកអប់ជាដើម។ អ្នកខ្លះថែមទាំងយកថ្នាំក្រហមទៅលាបក្រចក និងបបូរមាត់ ដោយសន្មត់ថាជាក្រែម និងថ្នាំក្រចកថ្វាយយាយទេពផង (រូបលេខ២៦)។

រូបលេខ២៦ រូបសំណាកយាយទេពសព្វថ្ងៃ

ដោយឡែក ចំពោះយាយទេពដ៏ល្បីល្បាញក្នុងវត្តយាយទេព (ឬវត្តទេពធីតារាម) ក្នុងខេត្តកំពង់ឆ្នាំង គឺមានលក្ខណៈខុសគ្នាស្រឡះពីយាយទេពកណ្តាលក្រុងសៀមរាប។ យាយទេពនេះ មានប្រវត្តិពាក់ព័ន្ធនឹងកំណើតវត្តដែលគេនិទានថា គាត់ជាអ្នកមានទ្រព្យស្តុកស្តម្ភ ជឿលុះនឹងសាសនា ហើយបានបរិច្ចាគដីសាងវត្ត ទើបមានឈ្មោះថា "វត្តយាយទេព"។ ប្រហែលដោយយកតាមនិទាននេះហើយ ទើបគេសង់បុស្បុកមួយយ៉ាងធំ តម្កល់បដិមាស៊ីម៉ងត៍ជាស្ត្រីសក់ខ្វី ពាក់វ៉ែនតា តុបតែងខ្លួនដោយអលង្ការស្អេកស្កះ ដូចជាអ្នកមានទ្រព្យស្តុកស្តម្ភដូចក្នុងនិទានប្រាកដមែន (រូបលេខ២៧)។ ចំពោះអ្នកស្រុក គេចាត់ទុកយាយទេពនៅទីនេះជាអ្នកថែរក្សាភូមិស្រុក និងផ្តល់ក្តីសុខសប្បាយ។ ក្នុងមួយឆ្នាំម្តងគេតែងធ្វើពិធីស្រង់ទឹកឱ្យយាយទេពនៅក្នុងរដូវចូលឆ្នាំខ្មែរ ដូចស្រង់ទឹកព្រះពុទ្ធរូបដែរ។ ក្នុងពិធីជាទំនៀមនេះ គេសម្គាល់ឃើញតែងតែមានវត្តមានថ្នាក់ដឹកនាំខេត្តចូលរួមជាអធិបតីផង (រូបលេខ២៨)។ ប្រការនេះបញ្ជាក់ច្បាស់ថា យាយទេពស្ថិតក្នុងវត្តយាយទេពក៏មានវិសាលភាពធំធេងណាស់ដែរក្នុងជំនឿរបស់អ្នកស្រុក និងថ្នាក់ដឹកនាំខេត្ត។

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត



រូបលេខ៧ រូបសំណាកយាយទេព



រូបលេខ៨ ពិធីស្រង់ទឹករូបសំណាកយាយទេព (ប្រភព៖ រដ្ឋបាលខេត្តកំពង់ឆ្នាំង)

បច្ចុប្បន្ន ឥទ្ធិពលនៃជំនឿយាយទេពទាំងពីរខាងលើ គេឃើញលេចឡើងនៅទីផ្សេងៗជាហូរហែ គួរនឹងលើកជាការសិក្សាពិចារណាទៅថ្ងៃមុខបាន។ រូបលេខ៩ គឺជាបដិមាយាយទេពឆ្លាក់តម្កល់នៅក្នុងវត្តភ្នៀត ស្ថិតក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ។ ចម្លាក់នេះ គឺចម្លងតាមរូបសំណាកយាយទេពក្បែរព្រះរាជដំណាក់ ខេត្តសៀមរាប ហើយថែមទាំងចារឹកអក្សរបញ្ជាក់ថា "បារមីលោកយាយទេព"។ រីឯរូបលេខ១០ គឺជារូបសំណាកយាយទេពតម្កល់ក្នុងវត្តល្វាក្រោម ស្ថិតក្នុងសង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ។ រូបនេះ គេសាងជារូបស្ត្រីចំណាស់ អង្គុយបញ្ឈរជង្គង់ម្ខាងដែរ។ នៅលើខ្នងមនោះមានចារអក្សរ "អាស្រមយាយទេព"។ ចំណែកឯរូបលេខ១១ ជាបដិមាចាក់ពុម្ពស៊ីម៉ងត៍តូចមួយ ដែលគេតម្កល់ក្នុងវត្តពីរល្វែង ស្ថិតក្នុងតំបន់ភ្នំវល្លិ ស្រុកដងទង់ ខេត្តកំពត។ រូបចុងក្រោយនេះ ជារូបតូចៗដែលគេធ្វើលក់យ៉ាងសម្បូណ៌បែប ហើយគេដឹងថាទើបនឹងមានវត្តមានក្នុងវត្តខាងលើកាលពីប៉ុន្មានឆ្នាំមុនប៉ុណ្ណោះ តែហាក់ពុំសំខាន់សម្រាប់អ្នកស្រុកឡើយ ដ្បិតគេដឹងថានៅរាល់ពាក់កណ្ដាលខែជេស្ឋ (រវាងខែមិថុនា) អ្នកស្រុកតែងធ្វើពិធីឡើងអ្នកតាបញ្ចូលបញ្ញាន់រូបនានាដើម្បីសុំទឹកភ្លៀង និងសុំសេចក្ដីសុខ។ ប៉ុន្តែចំពោះយាយទេពនេះ ពុំមានឃើញគេថ្វាយភ្លេង ឬហៅរកអ្វីសោះ។[៩] រូបសំណាកយាយទេពដែលមានសណ្ឋានផ្សេងៗបែបនេះ បើគេព្យាយាមសង្កេតតាមវត្តបច្ចុប្បន្ន តែងឃើញមានជានិច្ច តាមរយៈអ្នកចម្លាយទិញយកទៅថ្វាយវត្តជាអាទិ។

[៩] ហ៊ិន សារ៉េង ២០២០: ១៥-២០

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត








រូបលេខ៩ យាយទេពនៅវត្តភ្លៀត

រូបលេខ១០ យាយទេពនៅវត្តល្វាក្រោម

រូបលេខ១១ យាយទេពនៅវត្តពីរល្វែង

ជាសេចក្តីសង្កេត យាយទេពជាអមនុស្សភេទស្រីមួយដែលតែងស្ថិតនៅមិនឆ្ងាយពីវត្ត សូម្បីយាយទេពតាំងនៅក្បែរព្រះរាជដំណាក់ខេត្តសៀមរាប ក៏ស្ថិតនៅមិនឆ្ងាយពី "ព្រះអង្គចេកព្រះអង្គចម" តែហាក់ដូចជាមិនពាក់ព័ន្ធនឹងស្រែចម្ការឡើយ។ រីឯយាយទេពតាមវត្តផ្សេងៗទៀត ហាក់ដូចជាគេរៀបចំតម្រូវក្នែកទេសចរណ៍ ឬគិតថាក្នុងវត្តត្រូវតែមាន "ខ្ទមយាយទេព"។ ប៉ុន្តែបើសាកល្បងគិតអំពីជំនឿលើ "បារមីវត្ត" ឬ "បារមីព្រះ" យាយទេពប្រហែលជាមានចំណែកក្នុងទិដ្ឋភាពនេះ។[១០]

អរិយធម៌ខ្មែរ
KHMER CIVILIZATION

[១០] គំនិតនេះមានក្នុងការសិក្សាកន្លងមកខ្លះហើយ (អាំង ជូលាន ១៩៨៥:២១៩)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ហ៊ួន សាវង់

២០២០, "យាយម៉ៅនិងពិធីសុំទឹកភ្លៀងនៅភ្នំវល្លិ៍", *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ,* លេខ១៩, ទំ.១៥-២០, យសោធរ, ភ្នំពេញ

ហៀន សុវណ្ណមរកត

"ជំនឿលើព្រះគម្ពង់មុខវត្តឧណ្ណាលោម" ផ្សាយលើគេហទំព័រ

https://ams.com.kh/khmercivilization/detail/25553 ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២

អ៊ូ គន្ធា

"តាគង់ និងពិធីឡើងមាឃនៅវត្តខ្នាត" ផ្សាយលើតំណ

https://ams.com.kh/khmercivilization/detail/27077 ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

អាំង ជូលាន

២០០០, *មនុស្ស និងដី,* រៃយំ, ភ្នំពេញ

២០១២-២១៣, "មាន់ត្លាង", *កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ,* លេខ៨, ទំ.៣២-៣៦, Friends of Khmer Culture, ភ្នំពេញ

២០០៧, "សង្ខេបជំនឿលើព្រះយមរាជនៅប្រទេសកម្ពុជា", *ព្រឹត្តិបត្របុរាណវិទ្យា,* លេខ១, ទំ.២៥-៣៨, RUFA-UNESCO, ភ្នំពេញ

Ang Chouléan

1986, *Les êtres surnaturels dans la religion populaire khmère,* Cedoreck, Paris

Etienne Lunet de Lajonquière

1911, *Inventaire Descriptif des Monuments du Cambodage,* Ernest Leroux, Paris

Hang Chansophea

2004, "Stec Gaṃlaṅ' and Yāy Deb: Worshiping Kings and Queen in Cambodia Today", *History, Buddhism, and New Religious Movements in Cambodia,* pp.113-131, Silkworm Books, Bangkok